ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ផ្ទៃដីទំហំ ៧៩៣ ហិកតា ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដីពិតប្រាកដ ស្ថិតនៅក្នុងឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

**មាត្រា១ .-**

កាត់ផ្ទៃដីទំហំ ៧៩៣ ហិកតា ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដីពិតប្រាកដ ក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ (LASED III) ស្ថិតនៅក្នុងឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ខាងលើ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ដើម្បីធ្វើការគ្រប់គ្រង និងចាត់ចែងស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




| ID | X | Y |
|---|---|---|
| 1 | 478358.000 | 1445323.000 |
| 2 | 477345.000 | 1445323.000 |
| 3 | 477232.000 | 1445617.000 |
| 4 | 477381.000 | 1445832.000 |
| 5 | 477778.000 | 1445858.000 |
| 6 | 477755.000 | 1446400.000 |
| 7 | 477429.000 | 1446525.000 |
| 8 | 478302.000 | 1447759.000 |
| 9 | 478310.000 | 1447990.000 |
| 10 | 478895.000 | 1447927.000 |
| 11 | 479748.000 | 1448665.000 |
| 12 | 479913.000 | 1448556.000 |
| 13 | 480027.000 | 1448796.000 |
| 14 | 480057.480 | 1448673.004 |
| 15 | 480104.108 | 1448488.076 |
| 16 | 480151.331 | 1448300.793 |
| 17 | 480384.153 | 1447763.507 |
| 18 | 479822.000 | 1447436.000 |
| 19 | 479610.000 | 1446811.000 |
| 20 | 479549.000 | 1446302.000 |
| 21 | 479592.000 | 1446020.000 |
| 22 | 479389.000 | 1445344.000 |
| 23 | 479597.000 | 1445218.000 |
| 24 | 479579.002 | 1444920.950 |
| 25 | 479504.815 | 1444920.133 |
| 26 | 479225.318 | 1444902.366 |
| 27 | 479179.940 | 1445321.000 |
| 28 | 478903.000 | 1445321.000 |
| 29 | 478900.000 | 1445471.000 |
| 30 | 478738.000 | 1445484.000 |
| 31 | 478642.000 | 1445636.000 |
| 32 | 479789.012 | 1444923.262 |
| 33 | 479805.000 | 1445271.000 |
| 34 | 479779.000 | 1445358.000 |
| 35 | 479621.000 | 1445435.000 |
| 36 | 479804.000 | 1446016.000 |
| 37 | 479758.000 | 1446303.000 |
| 38 | 479825.000 | 1446769.000 |
| 39 | 479990.000 | 1447269.000 |
| 40 | 480475.300 | 1447553.167 |
| 41 | 480777.581 | 1447672.483 |
| 42 | 480881.108 | 1447434.667 |
| 43 | 481451.580 | 1447671.840 |
| 44 | 481690.886 | 1447074.109 |
| 45 | 481131.000 | 1446912.000 |
| 46 | 480963.000 | 1447026.000 |
| 47 | 480824.000 | 1447089.000 |
| 48 | 480640.000 | 1446986.000 |
| 49 | 480433.000 | 1446841.000 |
| 50 | 480396.000 | 1446684.000 |
| 51 | 480745.000 | 1446449.000 |
| 52 | 480640.000 | 1446296.000 |
| 53 | 480687.000 | 1446152.000 |
| 54 | 480210.000 | 1445921.000 |
| 55 | 480033.000 | 1445901.000 |
| 56 | 480009.000 | 1445691.000 |
| 57 | 480279.000 | 1445675.000 |
| 58 | 480294.237 | 1444928.824 |